អង្គការអ៊ីម័កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងភ្លើងចរាចរណ៍**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)

**ភាសាខ្មែរ**

ប្រើពាក្យសម្ដី និងកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង (ទំនាក់ទំនងដោយប្រើកាយវិការ និងនិមិត្តសញ្ញា)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**(ភាសាខ្មែរ)** អាចប្រាប់ពីនិមិត្តសញ្ញាសាធារណៈទៅអ្នកដទៃដើម្បីទំនាក់ទំនង។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “តើនរណាជាអ្នកលាបពណ៌មេឃ?”

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាស A4 ដែលមានពណ៌ក្រហម ពណ៌បៃតង លឿង កាត់ជារង្វង់ ក្រដាសកេះមួយផ្ទាំង និងក្រដាសរាមA4 ពណ៌សមួយសន្លឹក។

**ការរៀបចំ** ៖ ចោះក្រដាសកេះជា ៣រង្វង់ នៅលើក្រដាសកេះធ្វើជាភ្លើងស្តុបចរាចណ៍។បិទក្រសដាសពណ៌ក្រហមនៅរង្វង់ទីមួយលើគេបង្អស់ ពណ៌លឿងនៅកណ្តាល និងពណ៌បៃតងនៅខាងក្រោម។

**សេចក្ដីណែនាំ**៖

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងភ្លើងចរាចរណ៍**ជាមួយកូនៗទាំងអស់គ្នា។
2. ចែកក្មេងៗទៅជា ២ ឬ ៣ក្រុមទៅតាមចំនួនសិស្សនៅក្នុងថ្នាក់ និងទំហំបន្ទប់។
3. ឱ្យក្មេងៗឈរជាជួរក្នុងចំនួនដែលសមល្មមអាចនៅក្នុងបន្ទប់រៀន។
4. មានក្មេងម្នាក់នៅពីមុខជួរតំណាងជាអ្នកបើកបរ បន្ទាប់មកឈរបែរមុខមករកអ្នកគ្រូ។
5. អ្នកគ្រូកាន់ក្រដាសពណ៌ភ្លើងចរាចរណ៍។
6. ក្មេងៗត្រូវសម្តែងដូចជាពួកគេជាអ្នកបើកបរនូវលើដងផ្លូវអញ្ចឹងដែរ ហើយពួកគេត្រូវតែគោរពភ្លើងចរាចរណ៍។





7. ភ្លើងចរាចរណ៍មាន៖
   -ពណ៌ក្រហម មានន័យថាត្រូវឈប់នៅចំគំនូសដែលគេបានគូរនោះមិនត្រូវទៅមុខទៀតទេ។
   -ពណ៌លឿង មានន័យថា អាចទៅបាន តែត្រូវប្រុងប្រយ័ត្ន ងាមើលឆ្វេងមើលស្តាំមុននឹងចេញទៅ។
   -ពណ៌បៃតង មានន័យថា អាចទៅមុខបាន ។
8. បិទពណ៌លឿង និងពណ៌ក្រហម និងត្រូវបើកពណ៌បៃតង ឱ្យក្មេងៗត្រូវមើលភ្លើងចរាចរណ៍ហើយ អាចទៅមុខបាន។
9. ប្រាប់ក្មេងៗមុននឹងបើកបរទៅមុខត្រូវប្រុងប្រយ័ត្នជាមុនសិនមុនពេលទៅមុខ ។





10. ឱ្យក្មេងៗចាប់ផ្តើមបើកបរនៅជុំវិញថ្នាក់រៀន ឬកន្លែងណាដែលទូលាយក៏បាន។
11. ប៉ុន្មាននាទីក្រោយមកអ្នកគ្រូចាប់ផ្តើមផ្លាស់ប្តូរភ្លើងពណ៌ភ្លើងចរាចរណ៍៖
    -ពណ៌លឿងម្តងនឹងត្រូវបិទពណ៌ក្រហម និងពណ៌បៃតងដូច្នេះក្មេងៗត្រូវមានការប្រុងប្រយ័ត្ន ងាកមើលឆ្វេងមើលស្តាំ។
12. ផ្លាស់ប្តូរពណ៌ភ្លើងចរាចរណ៍ បើកពណ៌ក្រហម ត្រូវបិទពណ៌លឿង និងពណ៌បៃតង។ ក្មេងៗត្រូវឈប់ ដោយមិនត្រូវធ្វើដំណើរទៅមុខទៀតទេ។
13. ផ្លាស់ប្តូរបើកពណ៌បៃតង និងឱ្យក្មេងៗធ្វើជាបើកបរជុំវិញបន្ទប់រៀន។
14. ធ្វើបែបនេះរហូតដល់អ្នកគិតថាគ្រប់គ្រាន់ និងស្របទៅតាមពេលវេលា។